**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
**សភាព្រហ្មទណ្ឌ**
**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ២៤៨
ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៨
**សាលដីកា**
លេខ ៥៩ IV
ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០

**សាលដីកា**
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចខាងក្រោម៖

១.ឯកឧត្តម [redacted] ជាប្រធានក្រុមប្រឹក្សាជំនុំជម្រះ
២.លោក [redacted] ជាចៅក្រមរបាយការណ៍
៣.លោក [redacted] ជាចៅក្រម
៤.លោក [redacted] ជាចៅក្រម
៥.លោកស្រី [redacted] ជាចៅក្រម

**ក្រឡាបញ្ជីសវនាការ**

-កញ្ញា [redacted]

**តំណាងមហាអយ្យការ**

-លោក [redacted] ជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៣២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៥៨ ក្រ"រ" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមាន៖

ជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ ៤៧ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកម្មករសំណង់ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted] មានកូនចំនួន ០៣ នាក់ ជានីតិជន ទោសពីមុនគ្មាន។

មេធាវីលោក [redacted] ទិមុល ការពារសិទ្ធិ



Scanned with CamScanner

**ជាប់ចោទពីបទ** រំលោភសេពសន្ថវៈ ប្រព្រឹត្តនៅត្រង់ចំណុចភូមិកោះខ្នុរ ឃុំព្រែករកា ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៦ តាមបញ្ញត្តិ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **សុខច្ចាន** ភេទស្រី អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកណ្ដាល។

ជនរងគ្រោះឈ្មោះ [redacted] **ស្រីធីន** ភេទស្រី អាយុ ២០ ឆ្នាំ មុខរបរជាកម្មការនីរោងចក្រ មានទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តកណ្ដាល។

(អ្នកប្ដឹងសាទុក្ខ)

**អំពីអង្គហេតុ**

នៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ មានឈ្មោះ [redacted] សំអឿន បានបបួលលួងលោម ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន ឱ្យទៅរោងចិញ្ចឹមមាន់មួយកន្លែងស្ថិតនៅភូមិ [redacted] ខេត្តកណ្ដាល រួចបានធ្វើសកម្មភាពបង្ខិតបង្ខំ គំរាមកំហែង ដោយបានចាប់រំលោភសេពសន្ថវៈមកលើជនរងគ្រោះឈ្មោះ [redacted] ស្រីទីន រហូតដល់បានសម្រេច និងធ្វើសកម្មភាពចាប់រំលោភសេពសន្ថវៈជាបន្តបន្ទាប់ទៀត ដោយបានធ្វើការគំរាមកំហែងនិងបង្ខិតបង្ខំ រំលោកបានប្រហែល ១០០ ដង ទើបសមត្ថកិច្ចស្រាវជ្រាវ ធ្វើការឃាត់ខ្លួនបាន នៅថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៤៧ (គ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅៈ

១.ផ្ដន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] សំអឿន ភេទប្រុស អាយុ ៤៧ ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារចំនួន ០៦ (ប្រាំមួយ) ឆ្នាំ ជាប់ចោទពីបទៈ "រំលោភសេពសន្ថវៈ" ប្រព្រឹត្តនៅភូមិ [redacted] ខេត្តកណ្ដាល កាលពីថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៤ តាមបញ្ញត្តិមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ។

២.បង្គាប់ឱ្យជនជាប់ចោទ បង់សំណងជំងឺចិត្តចំនួន ៤ ០០០ ០០០ (បួនលាន) រៀលទៅឱ្យដើមបណ្ដឹងរដ្ឋប្បវេណី។ ច្រានចោលការទាមទារលើសពីនេះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

៣.សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។

-សម្រេចបើកផ្លូវប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

Scanned with CamScanner

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៦១៩ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ របស់ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន ប្ដឹងមិនសុខចិត្តទៅនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៧ (គ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ៥៨ក្រ៣ ៗ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១.ទទួលបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧ របស់ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខ្វះ នីងគតិច្បាប់ លើផលប្រយោជន៍ផ្នែករដ្ឋប្បវេណី និងមិនអាចទទួលយកបានលើផ្នែកអាជ្ញា។

២.តម្កល់ចំណុចទី២ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤៧ (គ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្ដាល ទុកជាបានការ។

៣.បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់។

-សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ និងជនរងគ្រោះ និងប្រកាសជាសាធារណៈ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨។ បើកសិទ្ធិប្ដឹងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្ដឹងសាទុក្ខលេខ ៣២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន ប្ដឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ ៥៨ក្រ៣ ៗ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទី២ នៃសេចក្ដីសម្រេចទាំងមូល។

**នាពេលសវនាការ**

-បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលសន្និដ្ឋានថា បណ្ដឹងសាទុក្ខបានធ្វើឡើងដោយ ដើមបណ្ដឹងជាជនរងគ្រោះ មិនសុខចិត្តនឹងសំណងចំនួន ៤ លានរៀល ដោយសាលាដំបូងនោះទេ ពីព្រោះធ្វើឱ្យខ្លួនបាត់បង់កិត្តិយស ក៏ប៉ុន្តែជនជាប់ចោទវិញបានអះអាងថាមិនមានលទ្ធភាពនោះទេ ហេតុដូច្នេះ គោលការណ៍សំណង ត្រូវមានលក្ខណៈសមល្មមនឹងព្យសនកម្ម នោះឃើញថា មានការសម្រេចឱ្យសង ៤ លានរៀល មានភាពតិចតួចនៅឡើយនូវព្យសនកម្ម ដែលបានកើតឡើង តែជនជាប់ចោទក៏គ្មានលទ្ធភាពផងដែរ។



Scanned with CamScanner

ហេតុដូច្នេះ តំណាងមហាអយ្យការប្តឹងសុំចំពោះតុលាការកំពូលឱ្យៈ

១.បណ្តឹងសាទុក្ខលេខ ៣៦៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ស្រីទីន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសទៅនឹងគតិច្បាប់។

២.តម្កល់សាលដីកាព្រហ្មទណ្ឌ ៥៨ក្រ॥"វ" ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន បានឆ្លើយថា ខ្លួនប្តឹងសាទុក្ខមកនេះគឺដោយសារតែខ្លួនមិនសុខចិត្តត្រង់សំណង ព្រោះខ្លួនទាមទារសំណងចំនួន ២០ លានរៀល តែសាលាដំបូងបានសម្រេចឱ្យខ្លួនតែ ២ លានរៀលទេ។ ខ្លួនទាមទារ ២០ លានរៀលនេះ គឺដោយសារតែទង្វើរបស់ជនជាប់ចោទធ្វើមកលើខ្លួនឃោរឃៅខ្លាំងណាស់។

-ជនជាប់ចោទឈ្មោះ [redacted] សំអឿន បានឆ្លើយថា បច្ចុប្បន្ននេះខ្លួនមានអាយុ ៥០ឆ្នាំហើយ ឪពុករបស់ខ្លួនឈ្មោះ [redacted] "ស" ហើយម្តាយឈ្មោះ [redacted] "ស" ចំណែកឯប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] មិនមែនឈ្មោះ [redacted] ទេ។ សព្វថ្ងៃខ្លួនគ្មានលុយនោះទេ ខ្លួនមានលទ្ធភាពសងត្រឹមតែ ២ លានរៀល នេះទេ ព្រោះខ្លួនមានមុខរបរពីមុនជាកម្មករសំណង់ ហើយគ្មានស្រែចំការទេ។

-ជនរងគ្រោះឈ្មោះ [redacted] ស្រីទីន បានឆ្លើយបន្ថែមថា ជនជាប់ចោទមានមុខរបរជាកម្មករសំណង់ពិតមែន ហើយក៏ជាប្រជាការពារក្នុងភូមិដែរ។

-ជនជាប់ចោទឈ្មោះ [redacted] សំអឿន បានឆ្លើយបន្ថែមថា ខ្លួននៅតែរក្សាសំណង ២ លានរៀល ដដែល។

-លោក [redacted] វិបុល មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សំអឿន បានធ្វើសេចក្តីសន្និដ្ឋានថា បណ្តឹងសាទុក្ខនេះទាក់ទងទៅនឹងសំណងរដ្ឋប្បវេណីតែប៉ុណ្ណោះ ហើយសាលាឧទ្ធរណ៍បានសម្រេចត្រឹមត្រូវហើយ ដូច្នេះខ្លួនសំណូមពរសុំឱ្យតុលាការកំពូលមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និង ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

## សំអាងហេតុ

១.យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៣២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់ជនរងគ្រោះ [redacted] ស្រីទីន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបាន តាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ មាត្រា ៤១៧ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២.យល់ឃើញថា នាពេលសវនាការនៅចំពោះមុខតុលាការកំពូលនេះ ជនរងគ្រោះ [redacted] ស្រីទីន ប្តឹងសាទុក្ខ និងសុំឱ្យតុលាការកំពូល សម្រេចឱ្យជនជាប់ចោទ [redacted] សំអឿន សងសំណងជំងឺចិត្តចំនួន ២០ ០០០ ០០០ រៀល ដោយលើកយកមូលហេតុថា ពេលរំលោភសេពសន្ថវៈ ខ្លួនមានអាយុទើបតែ ១២ ឆ្នាំ អំពើប្រព្រឹត្តមានលក្ខណៈធ្ងន់ធ្ងរ មិនអាចលុបលាងខ្លួនបានទេ នោះ តុលាការកំពូលពិនិត្យឃើញថា ការសម្រេចអំពីសំណងជំងឺចិត្តចំនួន ២ លានរៀលរបស់តុលាការអង្គហេតុមិនជូនល្មមទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលរង ក្នុងអំឡុងពេលដែលជនរងគ្រោះជាអនីតិជន គិតមកដល់ថ្ងៃប្រព្រឹត្តបទល្មើសអាយុទើបតែ ១២ ឆ្នាំ ០២ខែ ០២ថ្ងៃ មិនទាន់គ្រប់អាយុនៃការរួមភេទ ដែលតាមមាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌ នីតិភាពនៃការរួមភេទត្រូវបានកំណត់ចាប់ពីអាយុ ១៥ ឆ្នាំ ឡើងទៅ ជាហេតុនាំឱ្យប៉ះពាល់ដល់ផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ហើយដែលត្រូវមានការព្យាបាលខាងរូបកាយផង និង ព្យាបាលខាងផ្លូវចិត្តផងដោយប្រើពេលយូរថែមទៀត។ ដូច្នេះ តុលាការកំពូល គប្បីកែប្រែសំណងជំងឺចិត្តនេះឡើងវិញ ឱ្យបានជូនល្មមទៅនឹងព្យសនកម្មដែលជនរងគ្រោះបានទទួលរង តាមបញ្ញត្តិមាត្រា ៣០០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយមិនបង្អិល។

៣.យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៥៨ ក្រ.''វ'' ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីអំពីសំណងជំងឺចិត្តនេះ មិនត្រឹមត្រូវតាមច្បាប់។

## ហេតុដូច្នេះ

## សម្រេច

១.ទទួល បណ្តឹងសាទុក្ខលេខ ៣២៥ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ របស់ជនរងគ្រោះ [redacted] ស្រីទីន ។

២.តម្កល់ សាលដីកាព្រហ្មទណ្ឌលេខ ៥៨ ក្រ.''វ'' ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការ លើកលែងតែសេចក្តីសម្រេចចំណុចទី ២ ដែលតម្កល់ចំណុចទី ២ នៃសាលក្រមព្រហ្មទណ្ឌលេខ ៤៧ គ ចុះថ្ងៃទី២៨



Scanned with CamScanner

ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាល ទុកជាបានការ ត្រូវបដិសេធចោល និង សម្រេចជាថ្មី៖

-កែប្រែសេចក្តីសម្រេចចំណុចទី ២ នៃសេចក្តីសម្រេចនៃសាលក្រមព្រហ្មទណ្ឌ លេខ ៤៧ គ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកណ្តាលត្រង់សំណង ជំងឺចិត្តពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២០ និង ប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១១ ខែមីនា ឆ្នាំ២០២០។

Scanned with CamScanner